**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តស្វាយរៀង**
**គណៈកម្មាធិការលទ្ធកម្មរដ្ឋបាលខេត្ត**
**លេខៈ ០០២/១៩ សជណ**

## សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃការងារ

ក-ការងារកែលម្អច្រាំងទន្លេវ៉ៃគោ តាមបណ្តោយផ្លូវលេខ២០១ ( ទំនប់តាណេង )ចាប់ពីផ្លូវលេខ៣១៤ ទៅជើងទល់ផ្លូវលេខ១២០ ប្រវែង២០៥ម៉ែត្រ ស្ថិតនៅភូមិមេភ្លើង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង

ខ-ការងាររុះរើប័រឡេចាស់ និងរៀបថ្មីប្រវែង ១១០៦ម៉ែត្រ និងក្រាលកាវីឡាទំហំ ៣៧២០ម² ដែលមានទីតាំងដូចខាងក្រោមៈ

១-ការងារជួសជុលប័រឡេគែមផ្លូវប្រវែង ៣៧២ម៉ែត្រ និងក្រាលកាវីឡាទំហំ ៩១៨ម²នៅជុំវិញសួនកុមារខេត្ត។

២-ការងារជួសជុលប័រឡេគែមផ្លូវប្រវែង ៣៦៩ម៉ែត្រ និងក្រាលកាវីឡាទំហំ ៩៤៤ម²នៅខាងត្បូងនិងខាងលិចរបងមន្ទីរបក្សខេត្ត។

៣-ការងារជួសជុលប័រឡេគែមផ្លូវប្រវែង ២៨១ម៉ែត្រ និងក្រាលកាវីឡាទំហំ ១៣៧៤ម²នៅជុំខាងក្រោយសាលាខេត្តផ្លូវ២០៣។

៤-ការងារជួសជុលប័រឡេគែមផ្លូវប្រវែង៧៨ម៉ែត្រនិងក្រាលកាវីឡាទំហំ៤៤៨ម²នៅខាងត្បូងផ្លូវលេខ១២១និងខាងកើតផ្លូវ២០៣

៥-ការងារជួសជុលប័រឡេគែមផ្លូវប្រវែង៦ម៉ែត្រនិងក្រាលកាវីឡាទំហំ៣៦ម²នៅខាងមុខសាលាបឋមសិក្សាព្រះសីហនុ(មុខសាលាខេត្ត )

រដ្ឋបាលខេត្តស្វាយរៀង សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថាៈ រដ្ឋបាលខេត្តស្វាយរៀង នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បី ជ្រើសរើសអ្នកទទួលការៈ ក-ការងារកែលម្អច្រាំងទន្លេវ៉ៃគោ និងខ-ការងាររុះរើប័រឡេចាស់ និងរៀបថ្មីខាងលើជូនសាលាខេត្តស្វាយរៀង។

រដ្ឋបាលខេត្តស្វាយរៀង បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុនបំពេញ ដើម្បីចូលរួមដេញថ្លៃ និង មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋបាលខេត្តស្វាយរៀង អាសយដ្ឋានសាលាខេត្តស្វាយរៀង ចាប់ពីថ្ងៃទី...៤......ខែ.មករា....ឆ្នាំ២០១៩ រៀងរាល់ម៉ោងធ្វើការ ដល់វេលា ម៉ោង.................. ថ្ងៃទី.......ខែ...............ឆ្នាំ២០១៩ ។

ឯកសារដេញថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មរបស់រដ្ឋបាលខេត្តយ៉ាងយូរបំផុតត្រឹមថ្ងៃទី..៣....... ខែ.កុម្ភៈ....ឆ្នាំ២០១៩ វេលាម៉ោង.៩:៣០......។

ការបើកឯកសារដេញថ្លៃនឹងប្រព្រឹត្តទៅ នៅអង្គភាពលទ្ធកម្មរបស់រដ្ឋបាលខេត្ត តាមអាសយដ្ឋានខាងលើ ( សាលាខេត្តស្វាយរៀង) វេលាម៉ោង..៩:៣០.........ថ្ងៃទី...៣......ខែ.កុម្ភៈ....ឆ្នាំ២០១៩។

ក្រុមហ៊ុនដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬ មានប្រភពតែមួយអាចដាក់ឯកសារដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុនដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មរបស់រដ្ឋបាលខេត្តស្វាយរៀង ដើម្បីទិញឯកសារដេញថ្លៃ និង សាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ថ្ងៃពុធ...១៥កើត............ខែ.បុស្ស....ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

ស្វាយរៀង,ថ្ងៃទី....២០.......ខែ...មករា.....ឆ្នាំ២០១៩

**អភិបាលខេត្ត និងជា**
**ប្រធានគណៈកម្មាធិការលទ្ធកម្មរដ្ឋបាលខេត្ត**

**ម៉ែន វិបុល**

**ចម្លងជូន**
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារកាលប្បវត្តិ